# ទំនាស់ដ៏ក្ដៅគគុករវាង ខ្មែរ និង ថៃ

**ដោយ សន ជ័យសិទ្ធិ**

.នេះជាផែនទីឧបសម្ព័ន្ធ១ ដែលបារាំងធ្វើទុកឲ្យខ្មែរឆ្នាំ១៩០៤-១៩០៧ ដែលសៀមទទួលស្គាល់នៅឆ្នាំ១៩០៨ តាមការវិភាគរបស់តុលាការអន្តរជាតិក្រុងហេគ ។




.អូរតាខុប
.អូរតាត្រាវ
.ខ្សែបន្ទាត់ព្រំដែននៅខាងជើងភ្នំ
.នេះជាខ្សែបន្ទាត់ព្រំដែនរវាងសៀម និងខ្មែរ
. ភ្នំដែលសៀមតែងគូរផែនទីកាត់យក
.ប្រាសាទព្រះវិហារ




.នេះជាផែនទីសម័យសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧៣

.អូរតាខុប
.អូរតាត្រាវ
.ខ្សែបន្ទាត់ព្រំដែននៅខាងជើងភ្នំ
ភ្នំដែលសៀមតែងគូរផែនទីកាត់យក, ភ្នំស្រុប និងភ្នំព្រះវិហារ
.នេះជាខ្សែបន្ទាត់ព្រំដែនរវាងសៀម និងខ្មែរ
.ប្រាសាទព្រះវិហារ




នេះជាផែនទីដែលសៀមធ្វើនៅឆ្នាំ១៩៥៤

អូរតាខុប

អូរតាត្រាវ

ខ្សែបន្ទាត់ព្រំដែននៅខាងជើងភ្នំដែលសៀមបង្ខិតចូល

ភ្នំស្តុបដែលសៀមតែងគូរផែនទីកាត់យក

នេះជាខ្សែបន្ទាត់ព្រំដែនរវាងសៀម និងខ្មែរ

ភ្នំ និង ប្រាសាទព្រះវិហារ

នេះជាផែនទីដែលសៀមធ្វើនៅឆ្នាំ១៩៣៧ (១៩៣៤-១៩៣៥)




ផែនទីដែលសៀមបានយកទៅធ្វើជាភស្តុតាងក្នុងតុលាការអន្តរជាតិ នាទីក្រុងហេគ ឆ្នាំ១៩៦១-១៩៦២

1: 50.000 REDUCTION OF MAP SHEETS 1 AND 2 OF ANNEX 49

.នេះជាផែនទីដែលសៀមធ្វើនៅឆ្នាំ១៩៣៤-១៩៣៧




Map sheet 4 attached to annex 49

១ ខ្សែព្រំដែនផ្ទើរមគ្នា ១៩០៤-១៩០៧

២ ខ្សែព្រំដែនសម័យសាធារណរដ្ឋខ្មែរ១៩៧៣

៣ ព្រំដែនដែលសៀមធ្វើឆ្នាំ១៩៣៤-១៩៣៧

៤ ព្រំដែនដែលសៀមធ្វើឲ្យអាមេរិកាំងបោះតាម ឆ្នាំ១៩៥៤សៀមយកធ្វើទំនាស់នឹងខ្មែរសព្វថ្ងៃ

៥ ជ្រលង.អូរអៈម៉ារៀ ឬអូរតាខុបនៅខាងឆ្វេងដៃ អូរតាត្រាវនៅខាងស្ដាំដៃ(កន្លែងទំនាស់ក្នុង តុលាការនៃទីក្រុងហោគ

①② ភ្នំពីរដែលសៀមគួររំលោភកាត់យក

ខ្សែលេខ១ និងលេខ៣ និងអូរតាខុប តាត្រាវ(ខាងកើត) ជាចំណុចដែលតុលាការយកមកធ្វើការពិចារណាកាត់សេចក្ដីនៅឆ្នាំ១៩៦២។ តុលាការអន្តរជាតិក្រុងហោគ បានទាត់ចោលខ្សែព្រំដែនដែលសៀមចាត់ធ្វើ ហើយយកខ្សែព្រំដែនដែលបានផ្ទើរមគ្នារវាងសៀម-បារាំង នៅឆ្នាំ១៩០៤-១៩០៧ ជាផ្លូវការសម្រាប់កាត់ប្រាសាទព្រះវិហារមកជាកម្មសិទ្ធិ៍ពេញច្បាប់ជារបស់ខ្មែរ។ ទុកជាមោឃៈខ្សែ២,៣,និង៤។

# ទំនាស់នៃប្រាសាទព្រះវិហារ

# រវាងខ្មែរ និង សៀម

.សាលក្រមនៃតុលាការអន្តរជាតិ ដែលជារបស់អង្គការសហប្រជាជាតិ ដែលរៀបចំឡើងនៅទីក្រុងហោគ នៃប្រទេសនីហ្សេរឡង់ ។ គណៈចៅក្រម៩នាក់ក្នុងចំណោមចៅក្រម១២នាក់ បានកាត់ឲ្យកម្ពុជាមានអធិបតេយ្យភាពលើទឹកដីនៃព្រះវិហារ ។

តើហេតុផលអ្វីខ្លះដែលតុលាការអន្តរជាតិនេះបានសម្រេចសេចក្តីឲ្យខ្មែរឈ្នះ យកភស្តុតាង.អ្វីជាគោល?

ហេតុផលនិងភស្តុតាង ដែលខាងភាគីខ្មែរដាក់ជូនតុលាការអន្តរជាតិមានដូចតទៅ :

១. ផែនទីដែលជាលទ្ធផលនៃការធ្វើរួមគ្នារវាងភាគីសៀម និង ភាគីអាជ្ញាធរបារាំងតំណាងខាងខ្មែរសម័យអាណានិគមឆ្នាំ ១៩០៤-១៩០៧។

២. ផែនទីដែលចាត់ធ្វើរួចមកហើយនេះ បានផ្ញើឲ្យសៀមត្រួតពិនិត្យមើលដោយគ្មានធ្វើការលាក់លៀម។

៣. ខាងភាគីសៀមមិនបានធ្វើការតវ៉ាចំពោះផែនទីដែលផ្ញើទៅឲ្យនោះទេ ព្រមទាំងមានមានការសរសើទៀតផង ។

៤. ក្នុងការគូរផែនទីនេះ បារាំងយកចំណុចជ្រលងអូរខាងជើងភ្នំព្រះវិហារជាគោលសម្រាប់គូរ ដែលក្រោយមក សៀមថាជាការគូរខុសឆ្គងផ្សេងពីសន្និសញ្ញារួមគ្នារវាងភាគីទាំងពីរ តែខាងភាគីសៀមមិនបានធ្វើការតវ៉ាដល់គូភាគីខាងបារាំង(ខ្មែរ) ហើយសម្រេចគូរផែនទីផ្សេងទៀតដោយខ្លួនឯង ដោយអះអាងថាជ្រលងអូរនៅជើងភ្នំក្នុងស្រុកខ្មែរ ដោយមានប្រាសាទព្រះវិហារនៅក្នុងដីសៀមវិញ ដែលតុលាការថាជារឿងនឹកឃើញផ្ទាល់ខ្លួន ចាត់ទុកផែនទីនោះជាមោឃៈ ។ សូមមើលផែនទីដែលសៀមធ្វើដាក់ជូនតុលាការ ឧបសម្ព័ន្ធលេខ ៤៩។

៥. ព្រំដែនដែលយកជ្រលងដងអូរមកជាទីតាំងសម្រាប់គូរខ្សែបន្ទាត់ព្រំដែនរួមនេះ មានឃើញជ្រលងអូរពីរៈ ខាងឆ្វេងឈ្មោះអូរអៈម៉ារៀ និងខាងស្តាំឈ្មោះ .អូរតាត្រាវ។ បារាំងបានយកដងអូរទាំងពីនេះជាចំណុចព្រំដែននៃប្រទេសទាំងពីរ។

តុលាការអន្តរជាតិបានយកផែនទីឧបសម្ព័ន្ធ១នេះជាភស្តុតាងសំខាន់ក្នុងការវិនិច្ឆ័យថាប្រាសាទព្រះវិហារជាក់ស្តែងនៅក្នុងបូរណភាពទឹកដីនៃប្រទេសកម្ពុជា នៅថ្ងៃទី១៥ មិថុនា ១៩៦២។



បើតាមផែនទីនេះ យើងឃើញថា មិនថាឡើយតួអង្គប្រាសាទ សូម្បីតែចុងផុតនៃជណ្តើរនិងក្លោងទ្វារក៏នៅជ្រៅក្នុងទឹកដីខ្មែរដែរ ។ ហើយប្រាសាទតូចតាចដទៃទៀតព្រមទាំងស្រះទឹកអូរតាត្រាវក៏នៅក្នុងទឹកដីខ្មែរដូចគ្នា។ .បរិវេណដីដែលឧបសម្ព័ន្ធ១មានវិញសោត មានព្រំប្រទល់ឆ្ងាយដាច់ពីព្រះវិហារពេកណាស់ មិនមានជិតទៅនឹងតួប្រាសាទ .ដូចដែលសៀមគូរយកខ្លួនឯងកាត់ជណ្តើរកាំទី១៦២នោះទេ ។ សូមមើលផែនទីដែលសៀមធ្វើដោយអ្នកជំនាញការគេធ្វើ ដែលកាត់ចូលជ្រៅមកក្នុងដីខ្មែរកាត់ភ្នំព្រះវិហារជាងពាក់កណ្តាល និងភ្នំខាងលិចពាក់កណ្តាលទៀត(ផែនទីសៀមធ្វើនៅឆ្នាំ១៩៤០-១៩៥២ ហើយដែលបោះពុម្ពដោយ




រូបផែនទីទាំងនេះបានមកពីគេហទំព័រ ដែលគណបក្សសម រង្ស៊ី ផ្ញើកាលពីប៉ុន្មានសប្ដាហ៍មុន










ផ្ទៃដីដែលនៅមានទំនាស់

ផែនទីថ្មីដែលរដ្ឋាភិបាលខ្មែរគូរដាក់ព្រះវិហារជាបេតិកភ័ណ្ឌពិភពលោក

នេះជាផែនទីដែលខាងរាជរដ្ឋាភិបាលខ្មែរគូរដើម្បីដាក់ព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក

Http://www.cambodia.org/blogs/editorials/labels/Preah%20Vihear.html

.ដោយសេវាយោធាសហរដ្ឋអាមេរិកឆ្នាំ១៩៥៤ នៅទីក្រុងវ៉ាស្និងតុន ឌី.ស៊ី.។ ផែនទីនេះបានកាត់ភ្នំព្រះវិហារជាងពាក់កណ្ដាល (សូមមើលផែនទីត្រង់លេខ១ ក្នុងរង្វង់)ត្រង់កាំជណ្ដើរទី១៦២ ដែលប្រជាជនបាននិយាយអាងក្នុងគេហទំព័រនានារបស់ពួកគេ។ ត្រង់នេះជួនកាលខ្មែរយើងមិនបានធ្វើការចាប់អារម្មណ៍ផងក៏សឹងមាន ដោយគិតថា ព្រំប្រទល់ដែនរបស់ខ្លួននៅឯនាយតាមជ្រលងជងអូរអៈម៉ារៀ និងជ្រលងជងអូរតាត្រាវឯណោះ។ .តាមផែនទីនេះ ខ្សែព្រំដែនអូសទៅខាងលិចជាន់ពាក់កណ្ដាលកំពូលភ្នំមួយទៀតដែលនៅទិសពាយព្យភ្នំព្រះវិហារ។ ភ្នំនេះមានកម្ពស់៦០៣ម៉ែត្រពីកម្ពស់ទឹកសមុទ្រ ដែលខ្ពស់ប្រហាក់ប្រហែលគ្នានឹងភ្នំព្រះវិហារដែរ ។ តាមផែនទីឧបសម្ព័ន្ធ១ ភ្នំនេះនៅជ្រៅក្នុងដីខ្មែរប្រហែលចម្ងាយមួយគីឡូដីខាងលិចព្រំដែនផ្នែកខាងជើងភ្នំព្រះវិហារ ។

រដ្ឋាភិបាលសៀមហាក់ដូចជាក្ដៅក្រហាយខ្លាំងនឹងការកាត់ក្ដីរបស់តុលាការអន្តរជាតិនាទីក្រុងហេគនេះ ដែលមានផែនទីនៅជ្រៅក្នុងតំបន់អូរតាខុប ហើយបានបង្កើតផែនទីរបស់ខ្លួនមួយទៀត .នៅឆ្នាំ១៩៤០-១៩៥២ ដែលបោះពុម្ពនៅឆ្នាំ១៩៥៤ដោយសហរដ្ឋអាមេរិក យកទៅប្រាប់ប្រជាជនរបស់ខ្លួនថា .ផែនទីរវាងខ្មែរនឹងសៀមយ៉ាងត្រឹមត្រូវ ។ ខនេះដែលបណ្ដាលឲ្យប្រជាជនសៀមដែលគ្មានការយល់ដឹងពីរឿងក្ដីព្រះវិហារនៅពេលនោះ .យល់ឃើញថាខ្មែរជាអ្នកខូចរំលោភ .យកទឹកដីរបស់ខ្លួនរបូត ដែលតាមការពិតគឺជា .ចេតនាអាក្រក់ស្ដាមុខមាត់របស់ខ្លួន ដោយបំពានលើខ្មែរយើងម្ដងហើយម្ដងទៀតមិនចេះចប់ ជាភស្តុតាងជាក់ស្ដែងគឺការធ្វើផែនទីខុសពីសភាពពិតពីរបីលើកផ្សេងៗគ្នាស្រេចនឹងក្បាលចិត្ត ។ ប្រការនេះជាមូលហេតុមួយឲ្យប្រជាជនសៀមមានចិត្តចងគំនុំជាមួយប្រជាជនខ្មែរ ស្អប់ខ្ពើមនឹងមើលងាយខ្មែរមករហូត ហើយដែលតាមការពិតសៀមខ្លួនឯងជាអ្នកព្យាយាមបង្ករឡើងឲ្យមានគំនុំស្អប់ខ្ពើមដ៏អាក្រក់ ដោយគូរផែនទីមិនត្រឹមត្រូវ និងមិនជម្រាបប្រជាជនខ្លួនពីផែនទីត្រឹមត្រូវដែលតុលាការអន្តរជាតិកាត់ឲ្យនោះទេ ។

ខ្ញុំបានយកផែនទីដែលសៀមធ្វើ ក្នុងអត្រា១លើ ៥០,០០០ មកបញ្ចូលជាមួយខ្សែបន្ទាត់ព្រំដែននានាចាប់តាំងពីឆ្នាំ១៩០៤រហូតដល់សម័យខ្មែរ .សាធារណរដ្ឋដាក់បង្ហាញលោកអ្នកអានមើលគ្រាន់បានជាគំនិតពិចារណាជាមួយគ្នា។ .ផែនទីដែលខ្ញុំលើកយកមកបង្ហាញនៅពេលនេះមាន៤ គឺៈ (១) ផែនទីដែលបារាំងធ្វើ តាមអនុសញ្ញាឆ្នាំ១៨៩៣, ១៩០៤, និង១៩០៧ ដែលហៅថាផែនទីឧបសម្ព័ន្ធ១;(២) ផែនទីដែលសៀមធ្វើតាមការសម្រួតជាយដែនតំបន់វិវាទនេះ នៅឆ្នាំ១៩៣៤-១៩៣៥ ដែលសៀមដាក់ជូនតុលាការជាឧបសម្ព័ន្ធ៤៩; (៣) ផែនទីដែលសៀមធ្វើនៅឆ្នាំ១៩៥៤ ដែលសៀមតែងយកមកធ្វើជាទំនាស់ជាមួយខ្មែរពេលក្រោយៗមក; និង(៤) ផែនទីសម័យសាធារណរដ្ឋខ្មែរ ដែលសហរដ្ឋអាមេរិកចាត់ធ្វើឡើងសម្រាប់កងទ័ពអាកាសប្រតិបត្តិការនៅឆ្នាំ១៩៧៣។

ខ្ញុំនឹងយកផែនទីដែលសៀមធ្វើនៅឆ្នាំ១៩៣៤-១៩៣៥ ដែលហៅថាឧបសម្ព័ន្ធ៤៩ ដែលសៀមយកទៅបង្ហាញនៅតុលាការអន្តរជាតិឆ្នាំ៦១-៦២ មកធ្វើជាផ្ទៃខាងក្រោយសម្រាប់ជាផែនទីប្រៀបធៀបនឹងខ្សែព្រំដែនឆ្នាំផ្សេងៗរបស់សៀមទៅនឹងផែនទីដែលខ្មែរប្រកាន់យក(១៩០៤-១៩០៧) ដែលហៅថាឧបសម្ព័ន្ធ១ ជាផែនទីទី៥សម្រាប់



.ប្រើធ្វើការសិក្សាប្រៀបធៀបក្នុងទីនេះ។

ការសិកស្សាប្រៀបធៀបទៅលើផែនទីទី៥ដែល យកផែនទីឧបសម្ព័ន្ធ៤៩ដែលសៀមបានគូរដាក់ ជូនតុលាការអន្តរជាតិនៅពេលនោះ។ .នៅលើ ផែនទីនេះ សូមមើលខ្សែទី១ ដែលជាខ្សែព្រំដែន ដែលបារាំងបានចាត់ធ្វើឡើងរវាងឆ្នាំ១៩០៤-ឆ្នាំ១៩០៧ ដែលហៅថាឧបសម្ព័ន្ធ១ដែលបាន ចម្លងចេញយកមកដាក់នៅលើផែនទីដែលសៀម បានធ្វើនៅឆ្នាំ១៩៣៤-១៩៣៥ ដែលហៅ ថាឧបសម្ព័ន្ធ៤៩។ ខ្សែបន្ទាត់នេះ ដែលខាង .តុលាការរកឃើញថា .សៀមទទួលយល់ព្រមយក ផែនទីឧបសម្ព័ន្ធ១នេះ នៅឆ្នាំ១៩០៨-១៩០៩ មានអធិការកិច្ចពិនិត្យព្រំដែនចម្រុះ សៀម-បារាំងដើម្បីចាត់ធ្វើផែនទីនៅតំបន់នេះ ឲ្យកាន់តែមានភាពច្បាស់លាស់មែនទែន ត្រង់ខ្សែបន្ទាត់ដែលមានប្រាសាទព្រះវិហារ នៅក្នុងនោះ (សាលក្រម, ១៥ មិថុនា ៦២, ទំព័រ៣២ ភាសាអង់គ្លេស)។

តុលាការបានមានមតិថា .សៀមនិងបារាំង បានធ្វើសន្ធិសញ្ញាពាណិជ្ជកម្មជាមិត្តភាពនៅ ឆ្នាំ១៩២៥ និង ១៩២៧ សៀមមានឱកាស កាលណោះ .ដើម្បីលើកយកបញ្ហាជំទាស់ចំពោះ .ផែនទីឧបសម្ព័ន្ធ១ ដែលបារាំងបានធ្វើនោះ .តែ ផ្ទុយទៅវិញ សៀមមិនបានធ្វើការជំទាស់។ សន្ធិ-សញ្ញានេះបានធ្វើឡើងបន្ទាប់ពីសៀមបានធ្វើការ សម្រួតព្រំដែនផ្ទាល់របស់ខ្លួននៅឆ្នាំ១៩៣៤-១៩៣៥។ ហេតុផលនេះ ដែលតុលាសម្រេចថា .សៀមទទួលយល់ព្រមនឹងផែនទីឧបសម្ព័ន្ធ១ ដោយតុណ្ហីភាព(គ្មានការតវ៉ា)(Legal effect of silence as implying consent--Alleged non-concorrespondence of map line with true watershed)ដោយមិនគិតថាខ្សែជ្រលង អូរនោះនៅឯណាទេ (សាលក្រម, ១៥មិថុនា ១៩៦២ ទំព័រទី៦)។

ផែនទីដែលសៀមចាត់ធ្វើនេះ ស៊ីជ្រៅចូលមក ក្នុងដីខ្មែរ, សូមមើលខ្សែទី៣ក្នុងផែនទីប្រៀប ធៀបដែលធ្វើដោយអ្នកបច្ចេកទេសសៀម (1:50,000 Reduction of map sheet 1 and 2 of Annex 49)។ ខ្សែព្រំប្រទល់ពណ៌ ផ្សេងៗ មានប្រាប់ពេលនៃការរៀបចំគូរឡើង។ ខ្សែព្រំប្រទល់លេខ៣នេះ ជាផែនទីដែលសៀម យកមកទទល់ជាមួយខ្មែរ ដែលតុលាការអន្តរជាតិ .មានមតិភាគច្រើន៩ទល់នឹង៣កាត់ឲ្យខ្មែរយើង យកតាមផែនទីឧបសម្ព័ន្ធ១ឆ្នាំ១៩០៤-១៩០៧។

ផែនទីលេខ២ជាផែនទីធ្វើឡើងនៅសម័យសាធារ-ណរដ្ឋខ្មែរលោកសេនាប្រមុខលន់ នល់ ដោយ មជ្ឈមណ្ឌលផែនទីនៃក្រសួងការពារប្រទេស ក្រុង វ៉ាស៊ីងតុន ឌី.ស៊ី.។ ផែនទីនេះ មានខ្សែបន្ទាត់ខាង .ជើងភ្នំព្រះវិហារប្រហាក់ប្រហែលគ្នានឹងផែនទី ឧបសម្ព័ន្ធ១ឆ្នាំ១៩០៤-១៩០៧ដែរ ខុសគ្នា បន្តិចត្រង់ខ្សែបន្ទាត់ព្រំដែនខាងលិចស្រដៀងគ្នានឹង ផែនទីឧបសម្ព័ន្ធ៤៩របស់សៀម។ ប្រសិនបើខ្មែរ យើងយកផែនទីនេះជាផ្លូវការនិយាយជាមួយសៀម យើងនឹងអាចបាត់បង់ទឹកដីទៅប្រមាណពីរទៅ ពីរគីឡូម៉ែត្រក្រឡាកន្លះ។




ផែនទី៣ខ្សែទី៤ ជាខ្សែព្រំដែនដែលសៀមធ្វើនៅឆ្នាំ ១៩៤០-១៩៥២ តាមអត្រាពង្រួញ១លើ ៥០,០០០ ហើយបោះដោយសេវាកងទ័ពសហ-រដ្ឋអាមេរិកឆ្នាំ១៩៥៤។ ផែនទីនេះក៏មានលក្ខណៈ នៃការចាត់ធ្វើដែលមិនសមស្របនិងសន្ធិសញ្ញា .រវាងប្រទេសភាគីទាំងពីរដែរ។ រួមសេចក្តី គឺថា យកជាការមិនបានដូចគ្នា .ទោះបីឃើញប្រាសាទ

នៅក្នុងទឹកដីខ្មែរក៏ដោយចុះ ព្រោះព្រះវិហារទាំងមូលមិនបានមកជារបស់យើងទាំងអស់ ដែលផ្ទុយនឹងលក្ខណៈដែលមានក្នុងសន្ធិសញ្ញាទាំងបីលើកនោះៗ ប្រសិនបើ យើងយកផែនទីនេះជាគ្រឹះសម្រាប់ចរចាជាមួយសៀម យើងនឹងខាតបង់ផ្ទៃដីប្រហែលប្រមាណបួនគីឡូម៉ែត្រក្រឡា។

សូមជម្រាបថា តុលាការមិនបានយកផែនទីដែលមានលក្ខណៈដូចរៀបរាប់មកខាងលើ គឺផែនទីទាំងអស់ដែលមិនមែនជាឧបសម្ព័ន្ធ១ ដែលមានព្រំប្រទល់តាមជ្រលងដងអូរអៈម៉ារៀ ឬតាខុប និងជ្រលងអូរតាត្រាវ។ ម្យ៉ាងទៀត សូមបញ្ជាក់ថា ផែនទីរូបភាពព្រំប្រទល់ខ្មែរទី២ ជារបស់សម័យសាធារណរដ្ឋខ្មែរ ដែលពេលនោះខ្មែរយើងកំពុងមានសង្គ្រាមវាយគ្នាជាមួយពួកវៀតកុងនិងខ្មែរក្រហម រឿងព្រំប្រទល់ដែនអាចមានរឿងនិយាយគ្នាបានតិចបំផុត ឬក៏គ្មានពេលនឹងគិតផងក៏ថាបាន។

ដូចដែលបានជម្រាបហេតុផលត្រួសៗមកខាងលើ តើខ្មែរយើងគ្រប់រូបគួរដឹងថាដីរបស់យើងនៅម្តុំនេះមានព្រំប្រទល់នៅត្រង់ណា?

តាមមតិរបស់ខ្ញុំផ្ទាល់ យើងទាំងអស់គ្នាគួរយល់ថា តុលាការអន្តរជាតិក្រុងហេគ ដោយសម្លេងភាគច្រើន ៩ទល់នឹង៣ធ្វើការវិនិច្ឆ័យឲ្យព្រះវិហារមកខ្មែរយើង ដោយពឹងទៅលើភស្តុតាងផែនទីឧបសម្ព័ន្ធ១ដែលមានព្រំប្រទល់រត់តាមជ្រលងដងអូរអៈម៉ារៀ ហៅតាខុប និង ជ្រលងអូរតាត្រាវជាគ្រឹះនៃការសម្រេចសេចក្តី យើងទាំងអស់គ្នា គប្បីប្រកាន់យកការសម្រេចនៃតុលាការនៅពេលនោះ ថាជាព្រំប្រទល់របស់ខ្មែរនៅកន្លែងព្រះវិហារនេះ។

ប្រសិនបើការចរចានៃរាជរដ្ឋាភិបាលសព្វថ្ងៃក្លាយទៅជាប្រការផ្សេង បានលទ្ធផលមិនដូចដែលតុលាការអន្តរជាតិកាត់ក្តីនោះ យើងទាំងអស់គ្នាគួរនាំគ្នាជួយធ្វើឲ្យតុលាការអន្តរជាតិនេះ អនុវត្តសាលក្រមនេះ ដោយពង្រឹងនិងជម្រុញឲ្យសៀម (ថៃឡង់ដ៍)ធ្វើការគោរពដល់សាលក្រមនេះ ព្រោះសៀមជាសមាជិកនៃអង្គការសហប្រជាជាតិដូចខ្មែរយើងដែរ។ ម្យ៉ាងទៀត ក្នុងនាមខ្លួនខ្ញុំផ្ទាល់ អំពាវនាវសូមរាជរដ្ឋាភិបាលពង្រឹងជំហររបស់ខ្លួនលើផែនទីឧបសម្ព័ន្ធ១(Annex 1 map), មិនមែនផែនទីនានាដែលប្រទេសសៀម(ថៃ)ធ្វើឡើងដែលតុលាការអន្តរជាតិបដិសេធចោលហើយនោះទេ។

ផ្ទុយទៅវិញ បើយើងសុខចិត្តយកតាមផែនទីដែលសៀមគូរតាមអំពើចិត្តឲ្យយើងយកតាមនោះ យើងពិតជាគួរឲ្យអាណិត និងឆ្លាតតិចពេកហើយ ។

សន ជ័យសិទ្ធី

ឯកសារយោង


(១) ផែនទីឧបសម្ព័ន្ធ១ ដែលបារាំងធ្វើឡើងនៅឆ្នាំ១៩០៤-១៩០៧
http://www.icj-cij.org/docket/files/45/9249.pdf

(២) ផែនទីសម័យសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧៣
http://www.nexus.net/~911gfx/cambodia.html

(៣) ផែនទីសៀមធ្វើនៅឆ្នាំ១៩៥៤ (១៩៤០)
http://www.lib.utexas.edu/maps/ams/

(៤) ផែនទីសៀមធ្វើនៅឆ្នាំ១៩៣៧ (៣៤-៣៥)
http://www.icj-cij.org/docket/files/45/9249.pdf

(៥) សាលក្រមនៃតុលាការអន្តរជាតិ, ក្រុងហេគ, ប្រទេសនីហ្សេឡិន, អង្គការសហប្រជាជាតិ វិវាទរវាង ប្រទេសកម្ពុជា និង ប្រ.ថៃឡង់ដ៍
http://www.icj-cij.org/docket/index.php?p1=3&p2=3&code=ct&case=45&k=46

(៦) រូបថតប្រាសាទពីគេហទំព័ររបស់អាជ្ញាធរប្រាសាទព្រះវិហារ និងពីរបស់គេហទំព័សៀមៈ
Http://en.wikipedia.org/wiki/Image:Plan-preahvihear-1.png







ROYAUME DU CAMBODGE

# SCHEMA DIRECTEUR
# POUR LE ZONAGE DE PREAH VIHEAR

18-01-06

échelle = 1/40 000e




**LEGENDE**

- Route
- Frontière Internationale
- Contour 500m
- Ligne de 5km à partire du point Cone de vue

**Note explicative**

- 1 Zone monumentale de protection maximale
- 2 Zone tampon de protection et de cône de vue
- 3 Zone de développement

| Point | Latitude | Longitude |
|---|---|---|
| Core zone | | |
| 1 | 14°23´59´´ | 104°41´30´´ |
| 2 | 14 23 41 | 104 41 20 |
| 3 | 14 23 28 | 104 41 18 |
| 4 | 14 23 13 | 104 41 07 |
| 5 | 14 23 18 | 104 40 52 |
| 6 | 14 23 27 | 104 40 41 |
| 7 | 14 23 44 | 104 40 33 |
| 8 | 14 23 49 | 104 40 34 |
| 9 | 14 23 50 | 104 40 41 |
| 10 | 14 23 41 | 104 41 05 |
| Buffer zone | | |
| B | 14 22 19 | 104 42 48 |
| C | 14 22 34 | 104 40 02 |
| D | 14 23 22 | 104 40 08 |
| T | 14 23 16 | 104 42 12 |
| F | 14 22 37 | 104 40 39 |
| G | 14 22 29 | 104 41 32 |
| H | 14 22 07 | 104 43 15 |
| I | 14 21 23 | 104 43 03 |
| J | 14 21 12 | 104 42 51 |
| K | 14 20 56 | 104 42 29 |
| L | 14 20 55 | 104 39 40 |
| M | 14 21 07 | 104 39 09 |
| N | 14 21 49 | 104 38 29 |
| Point of cone de vue | | |
| O | 14 23 18 | 104 41 02 |

Source:
-Limite frontiere : Carte ' Dangrek ', echelle 1:200,000 de la Commission de Délimitation Franco-Siamoise
-Contour : carte UTM echelle 1 : 50 000 feuille 5937IV
-GPS handheld's survey .2002, 2005
-Satellite image SPOT . 1999
Geography Department.12.2002. Modification of 12.2005

http://bp2.blogger.com/_76xUgRgjZYM/SGKoX-Dv1FI/AAAAAAAAFCw/NLI7GLFIb5M/s1600-h/Preah_Vihear_French-13.jpg


LE TEMPLE DE PRÉAH VIHÉAR
CARTE ADMINISTRATIVE POUR LA GESTION PRÉPARÉE PAR LE ROYAUME DU CAMBODGE
EN VUE DE L'INSCRIPTION DANS LA LISTE DU PATRIMOINE MONDIAL
Échelle 1 : 10 000
440 460 480 500 520 540 560 580 600
500 520
600 580 560 540 520 500 480 460 440 420 400 380 360 340 320 300 280 260 240 220 200 180 160 140 120
1
2
3
LÉGENDE
Périmètre du Temple de Préah Vihéar (11ha)
Escalier ancien conduisant au Temple
Secteur N. 2
Secteur N. 3
Courbes de niveau
Rivières
250 0 250 Meters
Attachment To the Joint Communiqué dated June 18, 2008
N




**. កំណត់សម្គាល់**

**ខ្ញុំគ្មានទិន្នន័យចំពោះអត្រាទំហំរបស់ព្រះវិហារនេះទេ ។ ដូច្នេះការធ្វើផែនទីដែលគៀកជាប់នឹងតួជណ្តើរប្រាសាទនេះមានសភាពយ៉ាងណានោះខ្ញុំគ្មានយោបល់ទេ ។ តែរដ្ឋគួរធ្វើឱ្យមានឯកភាពគ្នានិងសុក្រិដ្ឋជាងនេះចំពោះអត្រាទំហំប្រាសាទនៅនឹងផ្ទៃដីក្នុងផែនទីទំនាស់**

**. ប្រៀបធៀបផែនទីនេះ នៅផែនទីនៅទំព័រទី១០ នឹងឃើញ**

**. ផលវិបាកនៃការគូរផែនទីនេះ។**

**. ផែនទីនេះចម្លងចេញពី(ទំព័រទី១១ក្នុងអត្ថបទនេះ) របស់ខ្មែរធ្វើថ្មី**